**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ការពន្យារពេលក្នុងការផ្សព្វផ្សាយរបាយការណ៍ប្រចាំឆ្នាំ ២០២១ របស់ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី

ក្រុមហ៊ុន **ជេអេស លែន ភីអិលស៊ី** ដែលជាក្រុមហ៊ុនអភិវឌ្ឍន៍អចលនទ្រព្យដំបូងគេក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានចុះបញ្ជីភាគហ៊ុនរបស់ខ្លួនជាមួយទីផ្សារកំណើននៃផ្សារមូលបត្រកម្ពុជា **"CSX"** មានកិត្តិយសសូមជម្រាបជូនដល់វិនិយោគិន និងសាធារណជនទាំងអស់អោយបានជ្រាបថា ក្រុមហ៊ុន **ជេអេស លែន ភីអិលស៊ី** នឹងពន្យារពេលការបង្ហាញរបាយការណ៍ប្រចាំឆ្នាំ២០២១របស់ខ្លួន។ ហេតុផលសម្រាប់ការយឺតយ៉ាវនេះ ដោយសារតែសវនករឯករាជ្យទើបតែបានផ្តល់នូវឯកសារព្រៀងនៃរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ឆ្នាំ ២០២១ ដល់ ក្រុមហ៊ុន **ជេអេស លែន ភីអិលស៊ី**។ សវនកររបស់យើងបានបង្ហាញឯកសារព្រៀងនៃរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ឆ្នាំ ២០២១ ដល់ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន **ជេអេស លែន ភីអិលស៊ី** ក្នុងកិច្ចប្រជុំនាថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២២ ដើម្បីទទួលបានការអនុម័ត។ បន្ទាប់ពីមានការយល់ព្រមពីក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន **ជេអេស លែន ភីអិលស៊ី** ក្រុមហ៊ុន **ជេអេស លែន ភីអិលស៊ី** នឹងទទួលបានរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០២១ ដែលបានធ្វើសវនកម្មរួចរាល់របស់ខ្លួននៅថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០២២។

ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ យើងខ្ញុំត្រូវការពេលវេលាខ្លះ សម្រាប់ការរៀបចំរបាយការណ៍ប្រចាំ ឆ្នាំ ហើយប៉ាន់ស្មានថា នឹងចេញ ផ្សាយជាសាធារណៈ នៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០២២។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមវិនិយោគិន និងសាធារណជនមេត្តាជ្រាបជាពត៌មាន។

រាជធានីភ្នំពេញ ថ្ងៃ សុក្រ ៦រោច ខែ ចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស
.២៥៦៥ ត្រូវនឹងថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០២២

**ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី**

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
ជេអេស លែន ភីអិលស៊ី
JS LAND PLC.
KINGDOM OF CAMBODIA